ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧០ សលប

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស "ទិវាសេរីភាពសារព័ត៌មានសកលលោក" លើកទី២៦ នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩

បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ សូមចូលរួមអបអរសាទរយ៉ាងកក់ក្តៅជាមួយបងប្អូនអ្នកសារព័ត៌មានជាតិ និងអ្នកសារព័ត៌មានអន្តរជាតិទាំងអស់ដែលកំពុងបំពេញការងារលើវិស័យសារព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅលើសកលលោកទាំងមូល ក្នុងឱកាសទិវាសេរីភាពសារព័ត៌មានសកលលោកដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី០៣ខែឧសភា ជារៀងរាល់ឆ្នាំ ក្នុងគោលបំណងលើកស្ទួយសេរីភាពនៃការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន និងធានាបាននូវសក្តានុពលការផ្សាយព័ត៌មានប្រកបដោយគុណភាព និងការទទួលខុសត្រូវតាមវិជ្ជាជីវៈ ដើម្បីជំរុញតួនាទីរបស់សារព័ត៌មានឲ្យកាន់តែសកម្មថែមទៀតក្នុងការចូលរួមចំណែករក្សាសុខសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍយ៉ាងពិតប្រាកដ។

ខួបលើកទី២៦ នៃទិវាសេរីភាពសារព័ត៌មានសកលលោកឆ្នាំនេះ បានផ្តោតលើប្រធានបទស្តីពី "តួនាទីប្រកបដោយសក្តានុពលរបស់សារព័ត៌មានក្នុងការគាំទ្រសន្តិភាព និងប្រជាធិបតេយ្យ" គឺពិតជាមានសារសំខាន់ស្របតាមបំណងប្រាថ្នា និងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាសកលលោកទាំងមូលដែលចង់បានសុខសន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍ ដែលផ្តើមចេញពីការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយដែលមានថាមពល និងការទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានពិតតាមវិជ្ជាជីវៈ ដើម្បីកសាងសង្គមមួយ ក៏ដូចជាពិភពលោកទាំងមូលឲ្យមានយុត្តិធម៌ សុខសន្តិភាព និងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យដើម្បីសម្រេចគោលដៅសន្តិភាព និងការអភិវឌ្ឍសកលលោកប្រកបដោយចីរភាព។

បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលបានខិតខំប្រឹងប្រែងបំពេញបេសកកម្មរបស់ខ្លួនក្នុងការផ្សព្វផ្សាយ និងចែករំលែកព័ត៌មានជូនប្រជាជនបានដឹង និងស្វែងយល់អំពីព្រឹត្តិការណ៍ដែលកំពុងមានការប្រែប្រួលនៅទូទាំងសកលលោកតម្រូវឲ្យអ្នកសារព័ត៌មានធ្វើការឆ្លើយតបឲ្យបានទាន់ពេលវេលាដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជន ដែលបច្ចុប្បន្នព័ត៌មានបានក្លាយទៅជាចំណីអាហារដែលគេចង់ដឹង ចង់ស្វែងយល់

អំពីសភាពការណ៍វិវឌ្ឍនៅលើសកលលោកទាំងបញ្ហានយោបាយ សេដ្ឋកិច្ច សង្គម និងបញ្ហាដទៃទៀត ដែលពាក់ព័ន្ធនឹងការរស់នៅ និងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។

ជាមួយគ្នានេះដែរ ខ្ញុំសូមកោតសរសើរចំពោះបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមបំពេញបេសកកម្មនៅក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តទៅកាលពីខែកក្កដា ២០១៨ កន្លងទៅថ្មីៗនេះ ដែលស្ថាប័នសារព័ត៌មានមួយចំនួនធំបានប្រកាន់ខ្ជាប់នូវក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មានក្នុងការផ្សព្វផ្សាយព័ត៌មានពិត ស្ដីពីការបោះឆ្នោតជូនប្រជាពលរដ្ឋ ដើម្បីធានាបរិយាកាសនយោបាយ និងដំណើរការនៃការបោះឆ្នោតបានប្រព្រឹត្តទៅប្រកបដោយភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ ហើយលទ្ធផលនៃការបោះឆ្នោតអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ ដែលឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដរបស់ប្រជា-ពលរដ្ឋ ធានាបាននូវសុខសន្តិភាពយូរអង្វែងនៅកម្ពុជា។ កត្តានេះបានបង្ហាញពីតួនាទីប្រកបដោយការទទួលខុសត្រូវរបស់សារព័ត៌មានក្នុងការគាំទ្រសន្តិភាព និងការអនុវត្តប្រជាធិបតេយ្យយ៉ាងពិតប្រាកដ។

ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតថា ក្នុងគោលដៅគាំពារ និងលើកស្ទួយសេរីភាពសារព័ត៌មាន និងផ្តល់តួនាទីឲ្យសារព័ត៌មានចូលរួមចំណែកកាន់តែសកម្មថែមទៀតក្នុងការអនុវត្តកំណែទម្រង់ស៊ីជម្រៅ អភិបាលកិច្ចល្អតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងដំណាក់ កាលទី៤ និងដើម្បីរក្សាសុខសន្តិភាព ប្រជាធិបតេយ្យនៅកម្ពុជា រាជរដ្ឋាភិបាលបានគោរពយ៉ាងហ្មត់ចត់តាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីរបបសារព័ត៌មាន ដែលធានាបាននូវសេរីភាពនៃការផ្សាយព័ត៌មានដោយគ្មានការត្រួតពិនិត្យជាមុន សិទ្ធិរក្សាការសម្ងាត់ស្តីពីប្រភពព័ត៌មានរបស់ខ្លួន សេរីភាពនៃការបញ្ចេញមតិដោយគ្មានទទួលទោសព្រហ្មទណ្ឌ និងអនុញ្ញាតឲ្យជនបរទេសធ្វើជាម្ចាស់ប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានគេមើលឃើញថា កម្ពុជា ជាប្រទេសដែលមានសេរីភាពខាងសារព័ត៌មានជាងប្រទេសដែលកាន់របបប្រជាធិបតេយ្យមួយចំនួននៅក្នុងតំបន់អាស៊ានទៀតផង។

ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលកម្ពុជា បានជំរុញឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធពន្លឿនការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និងធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មានឲ្យមានសង្គតិ-ភាពទៅនឹងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និងបទប្បញ្ញត្តិច្បាប់ដទៃទៀតដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិអនុម័តឲ្យបានឆាប់ដើម្បីធានាដល់ការអនុវត្តសិទ្ធិ សេរីភាពនៃការទទួលព័ត៌មាន សិទ្ធិ សេរីភាពនៃការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន និងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើងថែមទៀតក្នុងក្របខណ្ឌប្រជាធិបតេយ្យ សេរី ពហុបក្ស ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាទីស្រឡាញ់

ការបើកទូលាយនូវសេរីភាពសារព័ត៌មាននៅកម្ពុជា បានធ្វើឲ្យវិស័យនេះមានការរីកចំរើនលូតលាស់យ៉ាងឆាប់រហ័សទាំងសារព័ត៌មានបោះពុម្ពផ្សាយ សារព័ត៌មានអេឡិកត្រូនិក និងប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញដែលមាននិន្នាការផ្សេងៗគ្នាស្របតាមស្ថានភាពនយោបាយ និងការវិវឌ្ឍនៃបច្ចេកវិទ្យាទំនើបនាពេលបច្ចុប្បន្នដែលអាចផ្សព្វផ្សាយ និងចែករំលែកព័ត៌មានទូទាំងសកលលោកបានយ៉ាងឆាប់រហ័ស។

ដើម្បីឲ្យប្រព័ន្ធផ្សព្វផ្សាយប្រកបដោយសក្តានុពលក្នុងការគាំទ្រសន្តិភាព និងប្រជាធិបតេយ្យ គឺទាមទារឲ្យអ្នកសារព័ត៌មានទាំងអស់ ខិតខំប្រឹងប្រែងបន្តទៀតនូវការអភិវឌ្ឍសមត្ថភាពយល់ដឹងរបស់ខ្លួន និងមានភាពស្មោះត្រង់ក្នុងវិជ្ជាជីវៈ ក្លាហានហ៊ាននិយាយការពិត ធ្វើការរិះគន់ក្នុងន័យស្ថាបនា និងហ៊ានទទួលយកការពិតដើម្បីឲ្យព័ត៌មានរបស់ខ្លួនក្លាយជាព័ត៌មានពិតហើយធ្វើការឆ្លុះបញ្ចាំងឲ្យឃើញគ្រប់តថភាពសង្គមដើម្បីចូលរួមចំណែកកសាងសង្គមមួយឲ្យមានភាពយុត្តិធម៌ សុខសន្តិភាព និងមានការអភិវឌ្ឍដែលជាបំណងប្រាថ្នារបស់មនុស្សជាតិនៅទូទាំងសកលលោក។

មុននឹងបញ្ចប់ ខ្ញុំសូមអំពាវនាវដល់អ្នកសារព័ត៌មានជាតិ និងអ្នកសារព័ត៌មានបរទេសទាំងអស់ដែលកំពុងបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបំពេញការងារនៅបរទេសក្តី សូមយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈ ជៀសវាងការផ្សព្វផ្សាយព័ត៌មានតែមួយជ្រុងដោយមិនបានផ្ទៀងផ្ទាត់ព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ ហើយធ្វើការឆ្លុះបញ្ចាំងសភាពការណ៍ទាំងមូលដោយពុំបានគិតគូអំពីក្រឹត្យក្រមក្បួនខ្នាតនៃការសរសេរព័ត៌មាន ឬការផ្សាយព័ត៌មានក្លែងក្លាយដើម្បីបំប៉ោងសភាពការណ៍ និងបន្ទុះបង្អាប់ ញុះញង់អុជអាលឲ្យមានការស្អប់ខ្ពើម ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និន្នាការនយោបាយ ឬស្ថានភាពដទៃទៀត ដែលធ្វើឲ្យមានអវិភាពដល់ទំនាក់ទំនងជាមួយប្រទេសដទៃ បង្កឲ្យមានការបែកបាក់សាមគ្គីភាពផ្ទៃក្នុង ឬបង្កឲ្យមានទំនាស់ជាមួយបរទេសដែលធ្វើឲ្យអន្តរាយដល់ប្រទេសជាតិ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន និងត្រូវបន្តខិតខំអភិវឌ្ឍខ្លួនឲ្យមានសមត្ថភាពក្នុងការវិភាគសភាពការណ៍ទាំងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិឲ្យបានស៊ីជម្រៅ ដើម្បីដើរទាន់ការវិវឌ្ឍសភាពការណ៍ទាំងនៅក្នុងប្រទេស នៅក្នុងតំបន់ និងនៅលើសកលលោកនាពេលបច្ចុប្បន្ន និងសូមចូលរួមប្រយុទ្ធប្រឆាំងទៅនឹងព័ត៌មានក្លែងក្លាយដែលបង្កឡើងដោយជនអគតិមួយចំនួនដើម្បីបំរើមហិច្ឆតាលោភលន់របស់ខ្លួន កំពុងតែគំរាមកំហែងសុខសន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍនៅលើសកលលោកទាំងមូល។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរបងប្អូនអ្នកសារព័ត៌មានជាតិ និងអ្នកសារព័ត៌មានអន្តរជាតិទាំងអស់ទទួលបាននូវជោគជ័យក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងសូមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ។

ថ្ងៃអង្គារ ១១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**